ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
និង សង្គ្រោះជនពិការដោយសារមីន

លេខ :......✓........../..អន../..អធម../..២០២៦

# សេចក្តីថ្លែងការណ៍
## អាជ្ញាធរមីនបង្ហាញពីការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះកាតព្វកិច្ចនៃអនុសញ្ញាអូតាវ៉ា និងស្រាយបំភ្លឺលើករណីរកឃើញមីនប្រឆាំងមនុស្សនៅតំបន់ព្រំដែនកម្ពុជា-ថៃ

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) បានកត់សម្គាល់ឃើញ នូវការផ្សព្វផ្សាយជាសាធារណៈរបស់បណ្តាញសង្គមថៃ ដែលអះអាងថាបានដកស្រង់ ប្រភពពីយោធាថៃ ពាក់ព័ន្ធនឹងការរកឃើញមីនប្រឆាំងមនុស្សនៅតំបន់ព្រំដែន នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦។ អាជ្ញាធរមីន សូមបញ្ជាក់យ៉ាងមុតមាំថា កម្ពុជាបានអនុវត្តខ្ជាប់ខ្ជួនទៅតាមកាតព្វកិច្ចរបស់ខ្លួន ក្រោមគ្រប់កិច្ច ព្រមព្រៀងនិសញ្ញាវុធកម្មមនុស្សធម៌អន្តរជាតិ និងបន្តប្តេជ្ញាចិត្តយ៉ាងពេញលេញចំពោះការលុបបំបាត់មីនប្រឆាំង មនុស្សទាំងស្រុង។ កម្ពុជាសម្រេចបានសមិទ្ធផលធំធេង និងទទួលជាអន្តរជាតិ ក្នុងការបោសសម្អាតផ្ទៃដីរង ផលប៉ះពាល់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម និងនាំមកនូវសុខសុវត្ថិភាពជូនប្រជាជន និងសហគមន៍។

ផ្អែកលើទិន្នន័យជាតិ និងបទពិសោធន៍នៃការបោសសម្អាតមីននៅក្នុងតំបន់ព្រំដែន អាជ្ញាធរមីន អាចវាយតម្លៃបានថា មីនប្រឆាំងមនុស្សដែលត្រូវបានរកឃើញនៅក្នុងតំបន់ទាំងនោះ គឺជាមីនដែលបានបន្សល់ ពីសង្គ្រាមអតីតកាល ដែលសំណល់ជាតិផ្ទុះទាំងនោះ បានបង្កការគំរាមកំហែងយ៉ាងខ្លាំង អស់ជាច្រើនទសវត្សរ៍ ដល់ប្រជាជនរស់នៅតាមតំបន់ព្រំដែន។

អាជ្ញាធរមីន សូមគូសបញ្ជាក់ថា កម្ពុជាមិនផលិត មិនស្តុកទុក និងមិនប្រើប្រាស់មីនប្រឆាំងមនុស្សឡើយ និងមានការគ្រប់គ្រងត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ស្របតាមបទដ្ឋានអន្តរជាតិ។ ក្នុងន័យនេះ ការផ្សព្វផ្សាយដោយមិនមានប្រភពច្បាស់លាស់ ឬមិនមានការស៊ើបអង្កេត និងផ្ទៀតផ្ទាត់ត្រឹមត្រូវ អាចបង្កការភាន់ច្រឡំ និងអាចបង្កើនភាពតានតឹងដែលមិនចាំបាច់។

កម្ពុជាត្រៀមខ្លួនជាស្រេចក្នុងការចូលរួមប្រកបដោយតម្លាភាព ក្នុងយន្តការទ្វេភាគី និងអន្តរជាតិ ក្នុងការបញ្ជាក់ការពិត និងការពារមិនឱ្យមានភាពភាន់ច្រឡំណាមួយ។ សកម្មភាពមីនមនុស្សធម៌ គួរបម្រើដល់ផលប្រយោជន៍រួម ពោលគឺការពារប្រជាជន និងលើកកម្ពស់ស្ថិរភាពយូរអង្វែងនៅតាមបណ្តោយព្រំដែន។

អាជ្ញាធរមីន សូមបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តសម្រាប់កិច្ចសហប្រតិបត្តិការ កិច្ចពិភាក្សា និងការលុបបំបាត់នូវសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលបង្កការគំរាមកំហែងដល់អាយុជីវិតប្រជាជន និងសហគមន៍ក្នុងតំបន់ព្រំដែន។

ថ្ងៃ ពុធ ៩រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២៦

CMAA

អាសយដ្ឋាន : អគារថ្មី ផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទូលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ . ទូរស័ព្ទលេខ : ០២៣ ៨៨៥ ៩៤១ . ០២៣ ៨៨១ ៩៥២